ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ២២០៥ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៥

# ប្រកាស
## ស្តីពី
## ការផ្ទេរមុខងារ " ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ " ឲ្យទៅរដ្ឋបាលខេត្តបាត់ដំបង " ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល " ឲ្យទៅរដ្ឋបាលក្រុង ស្រុក និង " ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ " ឲ្យទៅរដ្ឋបាលឃុំ សង្កាត់ នៃខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២ ៦១ ០៣
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 72 61 03

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីដំណើរការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាល ក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារ ៖

- ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ឲ្យទៅរដ្ឋបាលខេត្តបាត់ដំបង
- ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ឲ្យទៅរដ្ឋបាលក្រុង ស្រុក នៃខេត្តបាត់ដំបងរួមមានៈ ក្រុងបាត់ដំបង ស្រុកសង្កែ ស្រុកឯកភ្នំ ស្រុកបាណន់ ស្រុករតនមណ្ឌល ស្រុកថ្មគោល ស្រុកបវេល ស្រុកមោងឫស្សី ស្រុកគាស់ក្រឡ ស្រុករុក្ខគីរី ស្រុកសំឡូត ស្រុកសំពៅលូន ស្រុកភ្នំព្រឹក និងស្រុកកំរៀង
- ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ ឲ្យទៅរដ្ឋបាលឃុំ សង្កាត់នៃខេត្តបាត់ដំបង

ដើម្បីគ្រប់គ្រងចាត់ចែង និងអនុវត្តសាកល្បងក្នុងរយៈពេល គិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

**ប្រការ ២.-**

កុមារដែលត្រូវការថែទាំនៅក្នុងមណ្ឌល និងថែទាំជំនួសនៅក្នុងសហគមន៍ គឺជាកុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ដូចជា៖

- កុមារដែលគ្មានឪពុកម្តាយ ឬអាណាព្យាបាលនៅជាមួយ
- កុមារបែកចេញពីគ្រួសារ ឬស្ថានភាពគំរាមកំហែងដែលអាចបណ្តាលឲ្យកុមារបែកចេញពីគ្រួសារ តាមរយៈការបោះបង់កុមារចោល ការជាប់ពន្ធនាគារ ការជួញដូរ ឬចំណាកស្រុក
- កុមារទទួលរងការប្រព្រឹត្តអំពើហិង្សា ឬការគម្រាម បង្កអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ឬការកេងប្រវ័ញ្ចគ្រប់រូបភាពដូចជាការលក់ ឬជួលកុមារជាដើម
- កុមារដែលឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួនពុំមានលទ្ធភាពបំពេញកាតព្វកិច្ចបីបាច់ថែរក្សាដោយសារការខ្វះខាតតម្រូវការចាំបាច់ និងសេវាមូលដ្ឋាន ទីជម្រក ចំណីអាហារ សម្លៀកបំពាក់ ការអប់រំ និងការថែទាំសុខភាព
- កុមារ ឬអ្នកថែទាំកុមារមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាពដែលធ្វើឲ្យកុមារមិនអាចទទួលបានការថែទាំសមស្រប
- កុមារដែលគ្រួសារញៀនគ្រឿងស្រវឹង លេងល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗដែលមិនអាចផ្តល់ការថែទាំសមស្របដល់កុមារ
- កុមារដែលកំពុងប្រឈម ឬកំពុងមានទំនាស់នឹងច្បាប់ ។

**ប្រការ ៣.-**

មុខងារ " **ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ** " សំដៅដល់ការគ្រប់គ្រង ចាត់ចែងឲ្យកុមាររស់នៅជុំគ្នាជាក្រុមក្រោមការថែទាំរបស់បុគ្គលិកដែលទទួលប្រាក់បៀវត្សរ៍ ដើម្បីផ្តល់អាហារ សម្លៀកបំពាក់ ថែទាំសុខភាព ការអប់រំ វិន័យ សីលធម៌ ការអភិវឌ្ឍក្នុងសង្គម ដោះស្រាយបញ្ហាផ្សេងទៀតរបស់កុមារ ។

មុខងារ " **ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល** " សំដៅដល់ការធ្វើអធិការកិច្ចលើការអនុវត្តសេវាថែទាំកុមារនៅក្នុងមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាលផ្ទៀងផ្ទាត់ទៅនឹងប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល។

មុខងារ " **ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍** " សំដៅដល់ការជួយអន្តរាគមន៍ និងដោះស្រាយដល់កុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍ ដោយចាត់ចែង និងសម្របសម្រួលផ្តល់នូវអាហារ សម្លៀកបំពាក់ ជម្រកសុវត្ថិភាព ការថែទាំសុខភាព ការអប់រំ វិន័យ សីលធម៌ ការអភិវឌ្ឍក្នុងសង្គម និងដោះស្រាយបញ្ហាផ្សេងៗទៀតរបស់កុមារ ដោយអនុវត្តប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ ស្តីពីបទដ្ឋានអប្បរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍។

**ប្រការ ៤.-**

ក្នុងអំឡុងពេលអនុវត្តសាកល្បងមុខងារខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នៃខេត្តបាត់ដំបង និងផ្នែកពាក់ព័ន្ធ ត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីការអនុវត្តសាកល្បងផ្ទេរមុខងារ **"ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល"** និង **"ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍"** របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ៥.-**

- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង ត្រូវត្រួតពិនិត្យ និងកំណត់ទំហំថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារ **ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ** និងសម្របសម្រួលជាមួយរដ្ឋបាលខេត្តដើម្បីរដ្ឋបាលខេត្តអាចផ្តល់ថវិកាបដិភាគ គាំទ្រអនុវត្តមុខងារនេះ។
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង ត្រូវត្រួតពិនិត្យ និងកំណត់ទំហំថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារ **ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល** និងសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក នៃខេត្តបាត់ដំបងដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក អាចផ្តល់ថវិកាបដិភាគ គាំទ្រអនុវត្តមុខងារនេះ។
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង និងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ នៃខេត្តបាត់ដំបង ត្រូវត្រួតពិនិត្យ និងកំណត់ទំហំថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារ **ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍** និងសម្របសម្រួលជាមួយរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់ អាចផ្តល់ថវិកាបដិភាគ គាំទ្រការអនុវត្តមុខងារនេះ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានបច្ចេកទេស ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែកពាក់ព័ន្ធ ត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារដល់រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នៃខេត្តបាត់ដំបង។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយដ្ឋានបច្ចេកទេស ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង ប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នៃខេត្តបាត់ដំបង មានភារកិច្ចអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**វង សូត**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប.

"ដើម្បីជូនជ្រាប"

- សាលាខេត្តបាត់ដំបង
- សាលាក្រុង ស្រុក នៃខេត្តបាត់ដំបង
- សាលាឃុំ សង្កាត់ នៃក្រុង ស្រុក ខេត្តបាត់ដំបង
- ដូចប្រការ ០៨

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ